# សណ្ដាប់សុចរិត

សុិស្ទើរ ឆើរីល ស៊ី ឡាន់
ប្រធានអង្គការបឋមសិក្សាទូទៅ

តើសណ្ដាប់ធ្នាប់ដែលយើងបង្កើតនៅក្រុមគ្រួសាររបស់យើង នឹងធ្វើឱ្យមានភាពងាយស្រួលចំពោះកូនៗរបស់យើងដើម្បីធ្វើតាមពួកព្យាការីដែលនៅរស់ដែរឬទេ?

តាមដែលខ្ញុំអាចចងចាំបាន ឪពុករបស់ខ្ញុំពាក់ចិញ្ចៀនត្បូងទទឹមពណ៌ក្រហមដ៏ស្អាតមួយ នៅលើដៃខាងឆ្វេងរបស់គាត់។ ចិញ្ចៀននោះបានឱ្យជាកេរមរតកដល់ប្អូនប្រុសរបស់ខ្ញុំ។ ខ្ញុំសន្មត់ថាវានឹងក្លាយជាសណ្ដាប់នៅក្នុងក្រុមគ្រួសាររបស់យើង ---កេរដំណែលដែលបានបន្តពីជំនាន់មួយទៅជំនាន់មួយ។ វានឹងក្លាយជាសណ្ដាប់ដ៏ល្អមួយ ជាមួយនឹងអនុស្សាវរីយ៍ដែល ជាប់ទាក់ទងទៅនឹងការផ្ដល់កេរដំណែលនេះ។

យើងម្នាក់ៗមានសណ្ដាប់នៅក្នុងក្រុមគ្រួសាររបស់យើង។ សណ្ដាប់ខ្លះគឺជាសម្ភារៈ។ សណ្ដាប់ខ្លះមានអត្ថន័យដ៏ជ្រាលជ្រៅ។ សណ្ដាប់ដ៏មានសារៈសំខាន់បំផុត គឺត្រូវបានភ្ជាប់ជាមួយនឹងវិធីដែលយើងរស់នៅក្នុងជីវិតរបស់យើង ហើយនឹងបន្សល់ទុកក្រោយពីជីវិតយើង នៅពេលដែលជីវិតនៃកូនចៅរបស់យើងត្រូវបានទទួលឥទ្ធិពល និងចេញជារូបរាង។ នៅក្នុងព្រះគម្ពីរមរមន យើងបានអានអំពីពួកសាសន៍លេមិន ដែលបានត្រូវជះឥទ្ធិពលយ៉ាងជ្រាលជ្រៅដោយសណ្ដាប់ពីពួកអយ្យកោរបស់ពួកគេ។ ស្ដេចបេនយ៉ាមីន បានមានបន្ទូលថា ពួកគេគឺជាមនុស្សដែលមិនដឹងអ្វីទាល់តែសោះអំពីគោលការណ៍ទាំងឡាយនៃដំណឹងល្អ "ព្រមទាំងមិនជឿនៅពេលពួកគេត្រូវបានបង្រៀនផង គឺដោយមកពីសណ្ដាប់ទាំងឡាយនៃពួកអយ្យកោរបស់គេដែលមិនត្រឹមត្រូវ" (ម៉ូសាយ 1:5)។

តើសណ្ដាប់ប្រភេទអ្វីដែលយើងមាន? សណ្ដាប់មួយចំនួនអាចមកពីពួកអយ្យកោ ហើយឥឡូវនេះយើងបន្តសណ្ដាប់ទាំងនេះដល់កូនចៅរបស់យើង។ តើសណ្ដាប់ទាំងនោះគឺដូចជាអ្វីដែលយើងចង់បានដែរឬទេ? តើសណ្ដាប់ទាំងនោះផ្អែកទៅលើសកម្មភាពនៃសេចក្ដីសុចរិត និងសេចក្ដីជំនឿដែរឬទេ? តើសណ្ដាប់ទាំងនោះភាគច្រើនជាសម្ភារៈក្នុងធម្មជាតិ ឬជាសណ្ដាប់ដ៏នៅអស់កល្បជានិច្ច? តើយើងបង្កើតសណ្ដាប់សុចរិតដោយមានស្មារតីដែរឬទេ ឬយើងគ្រាន់តែទទួលយកអ្វីៗដែលកើតឡើងចំពោះជីវិតរបស់យើង? តើសណ្ដាប់របស់យើងត្រូវបានបង្កើតក្នុងការឆ្លើយតបចំពោះសម្លេងខ្លាំងៗនៃពិភពលោក ឬតើសណ្ដាប់ទាំងឡាយត្រូវបានជះឥទ្ធិពលដោយសម្លេងតូចរហៀងនៃព្រះវិញ្ញាណដែរឬទេ? តើសណ្ដាប់ទាំងឡាយដែលយើងបង្កើតនៅក្នុងក្រុមគ្រួសាររបស់យើង នឹងធ្វើឱ្យមានលក្ខណៈងាយស្រួលចំពោះកូនចៅរបស់យើងដើម្បីធ្វើតាមពួកព្យាការីដែលនៅរស់ ឬតើសណ្ដាប់របស់យើងនឹងធ្វើឱ្យវាមានការលំបាកដល់ពួកគេដែរឬទេ?

តើយើងគួរតែកំណត់ថា សណ្ដាប់របស់យើងជាសណ្ដាប់បែបណាដែរឬទេ? ព្រះគម្ពីរបានផ្ដល់ឱ្យយើងនូវគំរូដ៏មហិមា។ នៅក្នុងម៉ូសាយ 5:15 បានថ្លែងថា "ហេតុដូច្នេះហើយ យើងចង់ឱ្យអ្នករាល់គ្នាតាំងចិត្តឱ្យខ្ជាប់ខ្ជួនហើយនឹងនរគឺ ពោរពេញទៅដោយអំពើល្អជានិច្ច"។

ខ្ញុំស្រឡាញ់ខគម្ពីរនេះ ពីព្រោះយើងដឹងថា សណ្ដាប់ទាំងឡាយ បានបង្កើតឡើងជាច្រើនដង នៅពេលយើងប្រព្រឹត្តដដែលៗម្ដងហើយម្ដងទៀត។ នៅពេលដែលយើងនឹងនរ ហើយមិនផ្លាស់ប្ដូរនៅក្នុងការធ្វើអ្វីដែលល្អ

នោះសណ្ដាប់របស់យើងក្លាយជាឬសរសរដ៏រឹងមាំនៅក្នុងសេចក្ដីសុចរិត ។ ប៉ុន្តែខ្ញុំមានសំណួរមួយ ។ តើយើងកំណត់អ្វីដែលល្អ ឬអ្វីដែលកាន់តែសំខាន់ទៅទៀតនោះដោយរបៀបណា? តើអ្វីខ្លះដែលល្អគ្រប់គ្រាន់? ខគម្ពីរដទៃទៀតបានផ្ដល់ឱ្យយើងនូវព័ត៌មានបន្ថែមបន្តិចបន្តួច ដែលមាននៅក្នុងនីហ្វៃទី3 6:14 ។ ខគម្ពីរនេះនិយាយអំពីមនុស្សដែល "បានប្រែចិត្តជឿចំពោះសេចក្ដីជំនឿពិត ហើយពួកគេពុំចាកចេញពីសេចក្ដីជំនឿពិតនោះឡើយ ព្រោះពួកគេរឹងប៉ឹង និងខ្ជាប់ខ្ជួន និងមុតមាំ ដោយសុខចិត្តធ្វើការព្យាយាមគ្រប់យ៉ាង ដើម្បីកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះអម្ចាស់" ។

យើងរៀនថា ការប្រែចិត្តជឿរបស់យើងចំពោះសេចក្ដីជំនឿពិត ដឹកនាំឱ្យសមត្ថភាពរបស់យើងរឹងប៉ឹង មាំមួន ហើយនឹងនរក្នុងការកាន់តាមព្រះបញ្ញត្តិទាំងឡាយ ។ ការប្រែចិត្តជឿនេះ គឺជាជំនឿដ៏រឹងមាំ ទៅលើព្រះយេស៊ូវគ្រីស្ទ ជាព្រះប្រោសលោះរបស់យើង ។ សាក្សីនេះគឺមាននៅក្នុងព្រះគម្ពីរមរមន ដែលជាសាក្សីមួយទៀតនៃព្រះយេស៊ូវគ្រីស្ទ ។ ព្រះគម្ពីរមរមនធ្វើការរួមគ្នាជាមួយនឹងព្រះគម្ពីរប៊ីប នៅក្នុងការប្រកាសនូវទេវភាព និងបេសកកម្មនៃព្រះយេស៊ូវគ្រីស្ទ ក៏ដូចជាការពិតនៃព្រះវរបិតាដែលគង់នៅស្ថានសួគ៌ផងដែរ ។ រាល់ព្យាការីបានកត់ត្រានៅក្នុងព្រះគម្ពីរពិសិដ្ឋនេះ ដោយផ្ដល់នូវសាក្សីផ្ទាល់ខ្លួនរបស់ពួកលោកអំពីកិច្ចការទាំងនេះ ក៏ដូចជាការបង្រៀនស្ដីពីរបៀបដែលយើងត្រូវរស់នៅក្នុងជីវិតរបស់យើង ដើម្បីទទួលបាននូវដង្វាយធួន ហើយស្វែងរកសេចក្ដីសុខសាន្ត និងសុភមង្គលផ្ទាល់ខ្លួន ។

មានតែវិធីមួយប៉ុណ្ណោះ ដើម្បីប្រែចិត្តជឿដោយផ្ទាល់ ។ ការប្រែចិត្តជឿមានតាមរយៈសាក្សីនៃព្រះវិញ្ញាណ នៅពេលដែលយើងសិក្សាព្រះគម្ពីរដ៏សំខាន់ទាំងនេះ ដែលថ្លែងអំពីព្រះយេស៊ូវគ្រីស្ទ ។ ការប្រែចិត្តជឿកើតមាន នៅពេលយើងអធិស្ឋាន និងនៅពេលយើងតមអាហារ ។ ការប្រែចិត្តជឿកើតមានតែនៅពេល យើងមានបំណងប្រាថ្នាដ៏ជ្រាលជ្រៅចង់ដឹងអំពីសេចក្ដីពិតប៉ុណ្ណោះ ។ ការជំរុញចិត្តរបស់យើងត្រូវតែស្វែងរកសេចក្ដីពិតដោយបើកចំហរ ជាជាងការគ្រាន់តែកែតំរូវសកម្មភាពរបស់យើង ដោយស្វែងរកកំហុសនៅក្នុងព្រះគម្ពីរទាំងឡាយ ក្នុងការបង្រៀននៃពួកព្យាការី ឬកំហុសរបស់សាសនាចក្រ ។ កិច្ចខិតខំរបស់យើងត្រូវតែឆ្ពោះទៅរកការបកប្រែនៃព្រះវិញ្ញាណ ជាជាងការយកចិត្តទុកដាក់នូវអ្វីដែលពិភពលោកយល់ ។ យើងត្រូវតែមានឆន្ទៈបើកដួងចិត្ត និងគំនិតរបស់យើងទទួលយកវិធីរបស់ព្រះអម្ចាស់ ហើយបើវាចាំបាច់ដើម្បីផ្លាស់ប្ដូរជីវិតរបស់យើង ។ ការប្រែចិត្តជឿផ្ទាល់ខ្លួនរបស់យើង កើតមាននៅពេលយើងចាប់ផ្ដើមរស់នៅតាមវិធីដែលព្រះអម្ចាស់សព្វព្រះទ័យចង់ឱ្យយើងរស់នៅតាម--- ដោយខ្ជាប់ខ្ជួន ហើយនឹងនរនៅក្នុងការគោរពតាមព្រះបញ្ញត្តិទាំងឡាយ ពុំមែនត្រឹមតែកិច្ចការដែលងាយស្រួលនោះឡើយ ។ ការណ៍នេះក្លាយជាដំណើរការនៃការដុសខាត់នៅពេលយើងព្យាយាមធ្វើឱ្យប្រសើរឡើងជាងមុនជារៀងរាល់ថ្ងៃ ។ ហេតុដូច្នេះហើយ សណ្ដាប់របស់យើងក្លាយជាសណ្ដាប់នៃសេចក្ដីសុចរិត ។

ខ្ញុំសូមអញ្ជើញយើងទាំងអស់គ្នាឱ្យចំណាយពេលគិតមួយភ្លែតអំពីសណ្ដាប់នៅក្នុងជីវិតរបស់យើង និងរបៀបដែលសណ្ដាប់ទាំងនេះ អាចជះឥទ្ធិពលដល់គ្រួសាររបស់យើង ។ សណ្ដាប់របស់យើងអំពីការរក្សាថ្ងៃឈប់សំរាកការអធិស្ឋានជាគ្រួសារ ការអានព្រះគម្ពីរជាគ្រួសារ ការបំរើ និងសកម្មភាពនៅក្នុងសាសនាចក្រ ក៏ដូចជាគំរូនៃការគោរព និងភក្ដីភាពនៅក្នុងផ្ទះនឹងជះឥទ្ធិពលយ៉ាងខ្លាំងទៅលើកូនចៅរបស់យើង ហើយចំពោះអនាគតរបស់ពួកគេ ។ បើការចិញ្ចឹមបីបាច់ថែរក្សារបស់យើងគឺផ្អែកទៅលើការបង្រៀននៃព្រះគម្ពីរទាំងឡាយ និងការបង្រៀនមកពីពួកព្យាការីថ្ងៃចុងក្រោយ នោះយើងនឹងពុំមានសណ្ដាប់ដែលខុសឡើយ ។ បើរាល់ពេលដែលមានឧបសគ្គ ដួងចិត្តរបស់យើងតែងតែងាករកព្រះវរបិតា

ដែលគង់នៅស្ថានសួគ៌ជាមុនសំរាប់ការណែនាំ នោះយើងនឹងស្ថិតនៅកន្លែងដែលមានសុវត្ថិភាព។ បើកូនចៅរបស់យើងដឹងពីកន្លែងដែលត្រូវឈរ ហើយតែងតែឈរនៅខាងព្រះអម្ចាស់ នោះយើងនឹងដឹងនូវកន្លែងដែលយើងត្រូវដើរទៅ។

ឥឡូវនេះ អ្វីដែលសំខាន់គឺថា យើងធ្វើការយ៉ាងខ្ជាប់ខ្ជួនដើម្បីធ្វើកិច្ចការទាំងនេះ។ យើងនឹងមិនភាពល្អឥតខ្ចោះចំពោះការណ៍ទាំងនេះនោះទេ ហើយក្រុមគ្រួសាររបស់យើង នឹងមិនតែងតែឆ្លើយតបដោយវិជ្ជមានជានិច្ចនោះដែរ ប៉ុន្តែយើងនឹងស្ថាបនា គ្រឹះដ៏រឹងមាំនៃសណ្ដាប់ដ៏សុចរិតមួយ ដែលកូនចៅរបស់យើងអាចពឹងផ្អែកបាន។ ពួកគេអាចតោងគ្រឹះនោះ នៅពេលដែលអ្វីៗមានភាពតានតឹង ហើយពួកគេអាចត្រឡប់ទៅរកគ្រឹះនោះវិញ បើពួកគេមានកំហុសអស់មួយរយៈពេល។

នៅចុងបញ្ចប់នៃជីវិតរបស់ឪពុករបស់ខ្ញុំ លោកបានបន្សល់ទុកឱ្យយើង ដែលជាកូនចៅរបស់លោកនូវអ្វីដែលមានតម្លៃលើសចិញ្ចៀនទទឹមត្បូងពណ៌ក្រហមទៅទៀត។ រូបកាយរបស់លោកបានសាបសូន្យទៅ ប៉ុន្តែការពិត លោកឈរធ្វើជាសរសរនៃកម្លាំង ជាគំរូនៃសេចក្ដីសុចរិត និងសេចក្ដីពិត។ ជីវិតរបស់លោកប្រកាន់នូវសណ្ដាប់ដែលពង្រឹងដល់ពួកយើងរហូតសព្វថ្ងៃនេះ ទោះបីជា លោកមិននៅជាមួយពួកយើងក្ដី។ លោកមានភាពខ្ជាប់ខ្ជួន ហើយនឹងនរដោយសុខចិត្តធ្វើការព្យាយាមគ្រប់យ៉ាង ដើម្បីកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះអម្ចាស់។

តើយើងអាចធ្វើការណ៍នេះសំរាប់កូនចៅរបស់យើងដែរឬទេ? តើអ្វីទៅជាកេរដំណែល ដែលយើងអាចផ្ដល់ឱ្យកូនចៅយើងនៅសព្វថ្ងៃនេះ? តើសណ្ដាប់នេះនឹងទៅជាយ៉ាងនៅថ្ងៃស្អែក? កិច្ចការនេះអាចចាប់ផ្ដើមជាមួយពួកយើង។ តើដួងចិត្ត និងជីវិត របស់ពួកគេពោរពេញដោយសណ្ដាប់ដែលផ្ដល់នូវភាពងាយស្រួលសំរាប់ពួកគេដើម្បីទទួលយក និងធ្វើតាមព្រះអម្ចាស់ និងពួកព្យាការីនៃសម័យចុងក្រោយដែរឬទេ? តើយើងនឹងធ្វើជាក្រុមគ្រួសារដែលអាចប្រកាសពរជ័យដែលបានសន្យាទុកដែលថា "ដើម្បីឱ្យព្រះគ្រីស្ទដែលជាព្រះអម្ចាស់ដ៏ជាព្រះដែលមានគ្រប់ព្រះចេស្ដា ទ្រង់បានភ្ជាប់អ្នកទុកជារបស់ផងទ្រង់ ដើម្បីឱ្យអ្នកបាននាំទៅកាន់ស្ថានសួគ៌ ដើម្បីឱ្យអ្នករាល់គ្នាបានសេចក្ដីសង្គ្រោះដ៏នៅអស់កល្បជានិច្ច និងជីវិតដ៏នៅអស់កល្ប" ដែរឬទេ? (ម៉ូសាយ 5:15)។

បងប្អូនប្រុសស្រីទាំងឡាយ ខ្ញុំដឹងថាយើងអាចធ្វើបាន! ខ្ញុំដឹងថាព្រះសព្វព្រះទ័យនឹងយើង ហើយរង់ចាំដើម្បីជួយយើងមកឯទ្រង់។ យើងម្នាក់ៗអាចដឹងថា កិច្ចការទាំងនេះពិត។ ខ្ញុំដឹងថាវាជាការពិត! ខ្ញុំដឹងថាព្រះមានព្រះជន្មរស់ព្រះយេស៊ូវគ្រីស្ទ គឺជាព្រះរាជបុត្រានៃព្រះ និងជាព្រះប្រោសលោះរបស់យើង។ ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ គឺពិតព្រះគម្ពីរមាននូវដំណឹងល្អនេះ ហើយខ្ញុំសូមថ្លែងទីបន្ទាល់ពីដំណឹងល្អនេះ។ ហើយយើងមានព្យាការីពិត ហើយនៅរស់សព្វថ្ងៃនេះ---ជាប្រធាន ថូម៉ាស អេស ម៉នសុន។ លោកបានត្រូវរៀបចំទុក ហើយបង្កើតឡើងនៅសព្វថ្ងៃនេះ ដើម្បីដឹកនាំសាសនាចក្ររបស់ព្រះអម្ចាស់។

នៅពេលដែលយើងមានភាពខ្ជាប់ខ្ជួន ហើយនឹងនរនៅក្នុងការគោរពតាមព្រះបញ្ញត្តិទាំងឡាយនៃព្រះអម្ចាស់ នោះយើងនឹងទទួលបានពរជ័យនៃស្ថានសួគ៌ទាំងនេះសំរាប់ខ្លួនរបស់យើង និងសំរាប់ក្រុមគ្រួសាររបស់យើង។

ខ្ញុំសូមអធិស្ឋានថាយើងនឹងទទួលបានអារម្មណ៍ដ៏ជ្រាលជ្រៅនេះនៅក្នុងដួងចិត្ត និងនៅក្នុងជីវិតរបស់យើង នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន។